ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ:...២១៧...ប្រក.ដ.ន.ស

# ប្រកាស

## ស្តីពី

## វិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel / Fax : 023 215 279 / (855-23) 215 660 / 023 217 031 គេហទំព័រ www.mlmupc.gov.kh /

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ ស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី ដើម្បីកំណត់អំពីលទ្ធភាពនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់សំណង់អគារគ្រប់ប្រភេទ។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរាល់គម្រោងអភិវឌ្ឍនិងការសាងសង់អគារនៅព្រះរាជាណាចក្រកម្ពុជា លើកលែងចំពោះសំណង់អគារទាំងឡាយណាដែលពុំតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

**ប្រការ ៤.-**

វាក្យស័ព្ទបច្ចេកទេសដែលប្រើក្នុងប្រកាសនេះមាននិយមន័យ ដូចខាងក្រោម៖

- **សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់មេគុណកំណត់ពីលទ្ធភាពនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់។
- **ផ្ទៃក្រឡាកម្រាលសំណង់សរុប** សំដៅដល់ផលបូកនៃផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់និង អគារដែលមាននៅក្នុងដីឡូត៍នៃគម្រោងសាងសង់។ ការគណនាផ្ទៃក្រឡាកម្រាលសំណង់ សរុបត្រូវគិតយកពីអ័ក្សនៃសសរ ឬជញ្ជាំងខាងក្រៅ។
- **ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ** សំដៅដល់ផ្ទៃក្រឡាកម្រាលសំណង់ដែលត្រូវគិតសន្ទស្សន៍ ដូចមានចែងក្នុងប្រការ៧នៃប្រកាសនេះ។
- **ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍គិតជាភាគរយ។

## ជំពូកទី ២
## វិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី

**ប្រការ ៥.-**

សន្ទស្សន៍ប្រើប្រាស់ដី ត្រូវកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះស្ថិតនៅ។

កាលណាសំណង់ថ្មីមួយត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ សន្ទស្សន៍ប្រើប្រាស់ដីត្រូវគណនាដោយបន្ថែមផ្ទៃក្រឡាកម្រាលនៃសំណង់ចាស់ទៅលើផ្ទៃក្រឡាកម្រាលនៃសំណង់ថ្មី។

$$\text{សន្ទស្សន៍ប្រើប្រាស់ដី} = \frac{\text{ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ}}{\text{ផ្ទៃក្រឡាដីឡូត៍}}$$

ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ = ផ្ទៃក្រឡាកម្រាលសំណង់សរុប – ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍។

**ប្រការ ៦.-**

របៀបគណនាជាក់ស្តែងនៃសន្ទស្សន៍ប្រើប្រាស់ដី ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ ផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៧.-**

ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ គឺជាផលបូកនៃផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់និងអគារដែលមាននៅក្នុងដីឡូត៍នៃគម្រោងសាងសង់ ដោយដកចេញនូវផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍។

ផ្ទៃក្រឡាសំណង់លើកលែងសន្ទស្សន៍ ជាអាទិ៍៖

- ផ្ទៃក្រឡាកម្រាលជាន់ក្រោមដីដែលមិនមែនជាបន្ទប់រស់នៅ
- ផ្ទៃក្រឡាកម្រាលជាន់ផ្ទាល់ដីដែលមានតែសសរតតមានរៀបជញ្ជាំង
- ផ្ទៃក្រឡាកម្រាលសំណង់លម្ហក្រោមដំបូលដែលមានកម្រិតកម្ពស់ទាបជាង១,៨០ (មួយម៉ែត្រប៉ែតសិប)
- ផ្ទៃក្រឡាលម្ហផ្តល់ពន្លឺ
- ផ្ទៃក្រឡាកម្រាលសួនច្បារខាងក្នុងអគារ
- ផ្ទៃក្រឡាកម្រាលសំណង់ដែលបម្រើសុខុមាលភាពសហគមន៍ក្នុងអគារលំនៅឋាន ដូចជាកន្លែងហាត់ប្រាណ អាងហែលទឹក បន្ទប់ស្ទីម បន្ទប់សូណា បន្ទប់ទឹក និងបន្ទប់ផ្លាស់សម្លៀកបំពាក់សម្រាប់ប្រើប្រាស់ក្នុងសហគមន៍
- ផ្ទៃក្រឡាកម្រាលដំបូលទេរ៉ាស់ រានហាល និងយ៉ក្នុងមុំពន្លឺ៤៥° (សែសិបប្រាំ) ដីក្រេ ដែលមានដំបូលនិងគ្មានជញ្ជាំងក្រៅ
- ផ្ទៃក្រឡាកម្រាលកន្លែងចំណតយានយន្ត រចនាសម្ព័ន្ធសម្រាប់ចំណតយានយន្ត និងកន្លែងទុកដាក់កាកសំណល់ ដែលមានជញ្ជាំងទាបជាង ១,៤០ (មួយម៉ែត្រសែសិប)
- ផ្ទៃក្រឡាកម្រាលសំណង់បន្ទប់ជណ្តើរ បន្ទប់អគ្គិសនី និងបន្ទប់មេកានិក
- ផ្ទៃក្រឡាកម្រាលដែលរៀបចំសម្រាប់ផលិតផលកសិកម្មប្រចាំគ្រួសារ សម្រាប់ចិញ្ចឹមសត្វនិងសម្ភារៈកសិកម្ម ក្នុងប្រភេទដីកម្រិតការសាងសង់។

ការគណនាផ្ទៃក្រឡាកម្រាលសំណង់សរុបសម្រាប់គណនាសន្ទស្សន៍ ត្រូវគណនាពីអ័ក្សនៃសសរឬជញ្ជាំងខាងក្រៅ។

## ជំពូកទី ៣
## អវសានបញ្ញត្តិ

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-**

នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...៣០... ខែ...ធ្នូ... ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួលៈ**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត

  **"ដើម្បីជូនជ្រាប"**
- ដូចប្រការ៩ **"ដើម្បីមុខការ"**
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធនៃប្រកាសលេខ ២១៧ប្រក.ដ.នស ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៥
# ស្តីពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី

## I. រូបមន្តវិធានគណនា

### ១.ការគណនាសន្ទស្សន៍ប្រើប្រាស់ដី

សន្ទស្សន៍ប្រើប្រាស់ដីត្រូវបានគណនាតាមរូបមន្តៈ

$$\mathbf{FAR} = \frac{\mathbf{FA_{TC}}}{\mathbf{SA_{T}}} \qquad (១)$$

- $\mathbf{FAR}$ (Floor Area Ratio) = សន្ទស្សន៍ប្រើប្រាស់ដី
- $\mathbf{FA_{TC}}$ (Total Covered Floor Areas) = ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ (ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍)
- $\mathbf{SA_{T}}$ (Total Site Area) = ផ្ទៃក្រឡាសរុបនៃដីឡូត៍ដែលសំណង់នោះតាំងនៅ

ឬ

$$\mathbf{FAR} = \frac{\mathbf{FA_{T}} - \mathbf{FA_{TUC}}}{\mathbf{SA_{T}}} \qquad (២)$$

__សម្គាល់:__ (១) និង (២)ជារូបមន្តទូទៅ ។

### ២.ការគណនាផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ

$$\mathbf{FA_{TC}} = \mathbf{FA_{T}} - \mathbf{FA_{TUC}} \qquad (៣)$$

- $\mathbf{FA_{T}}$ (Total Floor Areas) = ផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់
- $\mathbf{FA_{TUC}}$ (Total Uncovered Floor Areas) = ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍

__សម្គាល់:__ ការគណនា $\mathbf{FA_{TUC}}$ អនុវត្តតាមប្រការ៧ នៃប្រកាសនេះ។

### ៣.ការគណនាផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការនៃសន្ទស្សន៍ប្រើប្រាស់ដី

$$\mathbf{FA_{OL}} = \mathbf{FAR_{OL}} \times \mathbf{SA_{T}} \qquad (៤)$$

ដោយ ៖ $\mathbf{FAR_{OL}} = \mathbf{FAR_{P}} - \mathbf{FAR_{L}}$

ឬ

$$\mathbf{FA_{OL}} = \mathbf{FA_{P}} - \mathbf{FA_{L}} \qquad (៥)$$

ដោយ ៖ $\mathbf{FA_{L}} = \mathbf{FAR_{L}} \times \mathbf{SA_{T}}$

- $\mathbf{FA_{OL}}$ (Floor Area Over Limited) = ផ្ទៃក្រឡាកម្រាលសំណង់លើសសន្ទស្សន៍
- $\mathbf{FAR_{OL}}$ (Floor Area Ratio Over Limited) = សន្ទស្សន៍ប្រើប្រាស់ដីលើសការកំណត់ផ្លូវការ
- $\mathbf{FAR_{P}}$ (Floor Area Ratio Proposed) = សន្ទស្សន៍ប្រើប្រាស់ដីស្នើសុំដោយសាមីសំណើ
- $\mathbf{FAR_{L}}$ (Floor Area Ratio Limited) = សន្ទស្សន៍ប្រើប្រាស់ដីកំណត់ផ្លូវការ
- $\mathbf{FA_{P}}$ (Floor Areas Proposed) = ផ្ទៃក្រឡាកម្រាលសំណង់ស្នើសុំដោយសាមីសំណើ
- $\mathbf{FA_{L}}$ (Floor Areas limited) = ផ្ទៃក្រឡាកម្រាលសំណង់កំណត់ផ្លូវការ។

## II. ឧទាហរណ៍អំពីការគណនាសន្ទស្សន៍ប្រើប្រាស់ដី

### ក.ឧទាហរណ៍ទី១

#### ក១.តារាងគណនាសន្ទស្សន៍ប្រើប្រាស់ដី

–ឈ្មោះគម្រោង ៖....................

–ទីតាំង ៖ ស្ថិតនៅលើដីឡូត៍លេខ....................ផ្លូវលេខ..................ភូមិ....................ឃុំ/សង្កាត់......................ក្រុង/ស្រុក/ខណ្ឌ........................ រាជធានី/ខេត្ត.................................

| ល.រ | ឈ្មោះជាន់ | ផ្ទៃក្រឡាកម្រាលសំណង់តាមជាន់(ម²) | ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍តាមជាន់(ម²) | ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍តាមជាន់(ម²) | ផ្ទៃក្រឡាសរុបនៃដីឡូត៍(ម²) | សន្ទស្សន៍ប្រើប្រាស់ដីស្នើសុំ | សន្ទស្សន៍ប្រើប្រាស់ដីកំណត់ផ្លូវការ | សន្ទស្សន៍ប្រើប្រាស់ដីលើសការកំណត់ផ្លូវការ | ផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការនៃសន្ទស្សន៍ប្រើប្រាស់ដី(ម²) |
|---|---|---|---|---|---|---|---|---|---|
| ១ | ប្លង់ជាន់ផ្ទាល់ដី | ៧៤០,៩៦ | ១២៣,២៦ | ៦១៧,៧០ | | | | | |
| ២ | ប្លង់ជាន់ទី១ | ៨០៦,២៤ | ០,០០ | ៨០៦,២៤ | | | | | |
| ៣ | ប្លង់ជាន់ទី២ | ៨០៦,២៤ | ០,០០ | ៨០៦,២៤ | | | | | |
| ៤ | ប្លង់ជាន់ទី៣ | ៨០៤,០០ | ០,០០ | ៨០៤,០០ | | | | | |
| ៥ | ប្លង់ជាន់ទី៤ | ៧៥១,៥៧ | ៥៣៧,៤២ | ២១៤,១៥ | | | | | |
| ៦ | ប្លង់ជាន់ទី៥ | ៧៥១,៥៧ | ៥៥៤,៦១ | ១៩៦,៩៦ | | | | | |
| ៧ | ប្លង់ជាន់ទី៦ | ៧៥១,៥៧ | ៥៥៤,៦១ | ១៩៦,៩៦ | | | | | |
| ៨ | ប្លង់ជាន់ទី៧ | ៧៥១,៥៧ | ៥៥៤,៦១ | ១៩៦,៩៦ | | | | | |
| ៩ | ប្លង់ជាន់ទី៨ | ៧៥១,៥៧ | ៥៥៤,៦១ | ១៩៦,៩៦ | | | | | |
| ១០ | ប្លង់ជាន់ទី៩ | ៧៥១,៥៧ | ៥៥៤,៦១ | ១៩៦,៩៦ | | | | | |
| ១១ | ប្លង់ជាន់ទី១០ | ៧៥១,៥៧ | ៥៥៤,៦១ | ១៩៦,៩៦ | | | | | |
| ១២ | ប្លង់ជាន់ទី១១ | ៧៥១,៥៧ | ៥៥៤,៦១ | ១៩៦,៩៦ | | | | | |
| ១៣ | ប្លង់ជាន់ទី១២ | ៧៥១,៥៧ | ៥៧៨,១១ | ១៧៣,៤៦ | | | | | |
| ១៤ | ប្លង់ជាន់ទី១៣ | ៧៥០,២១ | ៥៦១,១៣ | ១៨៩,០៨ | | | | | |
| ១៥ | ប្លង់ជាន់ទី១៤ | ៧៥០,២១ | ៥៦១,១៣ | ១៨៩,០៨ | | | | | |
| ១៦ | ប្លង់ជាន់ទី១៥ | ៧៥០,២១ | ៥៦១,១៣ | ១៨៩,០៨ | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១៧ | ប្លង់ជាន់ទី១៦ | ៧៥០,២១ | ៥៦១,១៣ | ១៨៩,០៨ | | | | | |
| ១៨ | ប្លង់ជាន់ទី១៧ | ៧៥០,២១ | ៥៦១,១៣ | ១៨៩,០៨ | | | | | |
| ១៩ | ប្លង់ជាន់ទី១៨ | ៧៥០,២១ | ៥៦១,១៣ | ១៨៩,០៨ | | | | | |
| ២០ | ប្លង់ជាន់ទី១៩ | ៧៥០,២១ | ៥៦១,១៣ | ១៨៩,០៨ | | | | | |
| ២១ | ប្លង់ជាន់ទី២០ | ៧៥០,២១ | ៥៦១,១៣ | ១៨៩,០៨ | | | | | |
| ២២ | ប្លង់ជាន់ទី២១ | ៧៥០,២១ | ៥៦១,១៣ | ១៨៩,០៨ | | | | | |
| ២៣ | ប្លង់ជាន់ទី២២ | ៧៥០,២១ | ៥៦១,១៣ | ១៨៩,០៨ | | | | | |
| ២៤ | ប្លង់ជាន់ទី២៣ | ៧៤៥,៧០ | ៥៧០,១៦ | ១៧៥,៥៤ | | | | | |
| ២៥ | ប្លង់ជាន់ទី២៤ | ៧៤៥,៧០ | ៥៧០,១៦ | ១៧៥,៥៤ | | | | | |
| ២៦ | ប្លង់ជាន់ទី២៥ | ៧៤៥,៧០ | ៥៧០,១៦ | ១៧៥,៥៤ | | | | | |
| ២៧ | ប្លង់ជាន់ទី២៦ | ៧៦៥,៨០ | ៥៤០,៩១ | ២២៤,៨៩ | | | | | |
| ២៨ | ប្លង់ទៅក់ស់ដំបូល | ១២៧,៨២ | ០,០០ | ១២៧,៨២ | | | | | |
| សរុប | | ២០.៥៥៤,៣៩ | ១២.៩៨៣,៧៥ | ៧.៥៧០,៦៤ | ១.១៧៥,០០ | ១១,០៥ | ៥ | ៦,០៥ | ៧.១០៨,៧៥ |
| | | $FA_T$ | $FA_{TC}$ ឬ $FA_P$ | $FA_{TUC}$ | $SA_T$ | $FAR_P$ | $FAR_L$ | $FAR_{OL}$ | $FA_{OL}$ |

**ក២.ការគណនាតាមរូបមន្ត**

**១.ការគណនាសន្ទស្សន៍ប្រើប្រាស់ដី**

- ឈ្មោះគម្រោង ៖ អគារស្នាក់នៅ
- ទីតាំង ៖ ស្ថិតក្នុងតំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់
- ផ្ទៃក្រឡាសរុបនៃដីឡូត៍ **($SA_T$)** = ១.១៧៥,០០ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់ **($FA_T$)** = ២០.៥៥៤,៣៩ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ **($FA_{TC}$)** = ១២.៩៨៣,៧៥ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **($FA_{TUC}$)** = ៧.៥៧០,៦៤ ម៉ែត្រក្រឡា

តាមរយៈរូបមន្ត $$FAR = \frac{FA_{TC}}{SA_T}$$

ដូចនេះ សន្ទស្សន៍ប្រើប្រាស់ដី **(FAR)** $= \frac{១២.៩៨៣,៧៥}{១.១៧៥,០០} =$ <u>១១,០៥</u> (១)

ឬ តាមរយៈរូបមន្ត $$FAR = \frac{FA_T - FA_{TUC}}{SA_T}$$

ដូចនេះ សន្ទស្សន៍ប្រើប្រាស់ដី **(FAR)** $= \frac{២០.៥៥៤,៣៩ - ៧.៥៧០,៦៤}{១.១៧៥,០០} =$ <u>១១,០៥</u> (២)

**២.ការគណនាផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ**

តាមរយៈរូបមន្ត $FA_{TC} = FA_T - FA_{TUC}$

ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ **($FA_{TC}$)** = ២០.៥៥៤,៣៩ – ៧.៥៧០,៦៤

= <u>១២.៩៨៣,៧៥</u> ម៉ែត្រក្រឡា (៣)

**៣.ការគណនាផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការនៃសន្ទស្សន៍ប្រើប្រាស់ដី**

តាមរយៈរូបមន្ត $FA_{OL} = FAR_{OL} \times SA_T$

ដោយ៖ $FAR_{OL} = FAR_P - FAR_L$

- សន្ទស្សន៍ប្រើប្រាស់ដីស្នើសុំ **($FAR_P$)** = ១១,០៥
- សន្ទស្សន៍ប្រើប្រាស់ដីកំណត់ផ្លូវការ **($FAR_L$)** = ៥

យោងតាមមាត្រា២២នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន **តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់** ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើ៥។

នាំឲ្យ សន្ទស្សន៍ប្រើប្រាស់ដីលើសការកំណត់ផ្លូវការ **($FAR_{OL}$)** = **១១,០៥ – ៥** = **៦,០៥**

ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់លើសសន្ទស្សន៍ **($FA_{OL}$)**= **៦,០៥ x ១.១៧៥,០០**

= **<u>៧.១០៨,៧៥</u>** ម៉ែត្រក្រឡា (៤)

ឬ តាមរយៈរូបមន្ត **$FA_{OL}$ = $FA_P$ – $FA_L$**

– ផ្ទៃក្រឡាកម្រាលសំណង់ស្នើសុំដោយសាមីសំណើ **($FA_P$)**ឬ **($FA_{TC}$)** = **១២.៩៨៣,៧៥** ម៉ែត្រក្រឡា

– ផ្ទៃក្រឡាកម្រាលសំណង់កំណត់ផ្លូវការ **($FA_L$)** = **$FAR_L$ x $SA_T$**

= **៥ x ១.១៧៥,០០**

= **៥.៨៧៥,០០** ម៉ែត្រក្រឡា

ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់លើសសន្ទស្សន៍ **($FA_{OL}$)**=**១២.៩៨៣,៧៥ – ៥.៨៧៥,០០**

= **<u>៧.១០៨,៧៥</u>** ម៉ែត្រក្រឡា (៥)

## ក៣.ប្លង់ស្ថាបត្យកម្មគម្រោងស្នើសុំសាងសង់(ឧទាហរណ៍ទី១)




**ប្លង់ជាន់ផ្ទាល់ដី**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់ជាន់ទី១**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់ជាន់ទី២**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់ជាន់ទី៣**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់ជាន់ទី៤**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់ជាន់ទី៥ ដល់ជាន់ទី១១**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់ជាន់ទី១២**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់ជាន់ទី១៣,១៥,១៧,១៩,២១**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់ជាន់ទី១៤,១៦,១៨,២០,២២**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់ជាន់ទី២៣,២៤,២៥**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់ជាន់ទី២៦**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍




**ប្លង់តេរ៉ាស់ដំបូល**

ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍

## ខ.ឧទាហរណ៍ទី២

### ខ១.តារាងគណនាសន្ទស្សន៍ប្រើប្រាស់ដី

–ឈ្មោះគម្រោង ៖…………………

–ទីតាំង ៖ ស្ថិតនៅលើដីឡូត៍លេខ…………………ផ្លូវលេខ………………ភូមិ…………………ឃុំ/សង្កាត់……………………ក្រុង/ស្រុក/ខណ្ឌ……………………
រាជធានី/ខេត្ត………………………………

| ល.រ | ឈ្មោះជាន់ | ផ្ទៃក្រឡាកម្រាលសំណង់តាមជាន់(ម²) | ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍តាមជាន់(ម²) | ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍តាមជាន់(ម²) | ផ្ទៃក្រឡាសរុបនៃដីឡូតិ៍(ម²) | សន្ទស្សន៍ប្រើប្រាស់ដីស្នើសុំ | សន្ទស្សន៍ប្រើប្រាស់ដីកំណត់ផ្លូវការ | សន្ទស្សន៍ប្រើប្រាស់ដីលើសការកំណត់ផ្លូវការ | ផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការនៃសន្ទស្សន៍ប្រើប្រាស់ដី(ម²) |
|---|---|---|---|---|---|---|---|---|---|
| ១ | ប្លង់ជាន់ក្រោមដី | ៤២៦៦,១០ | 0,00 | ៤២៦៦,១០ | | | | | |
| ២ | ប្លង់ជាន់ផ្ទាល់ដី | ៣៦០០,៨០ | ១៩២៥,០៤ | ១៦៧៥,៧៦ | | | | | |
| ៣ | ប្លង់ជាន់ទី១ | ៤២៧៤,៤៥ | ១៩៨៦,៩២ | ២២៨៧,៥៣ | | | | | |
| ៤ | ប្លង់ជាន់ទី២ | ៤៣០៨,៦៥ | 0,00 | ៤៣០៨,៦៥ | | | | | |
| ៥ | ប្លង់ជាន់ទី៣ | ៤២៩៦,១៧ | 0,00 | ៤២៩៦,១៧ | | | | | |
| ៦ | ប្លង់ជាន់ទី៤ | ៤២៩៦,១៧ | ៥៩៩,៧១ | ៣៦៩៦,៤៦ | | | | | |
| ៧ | ប្លង់ជាន់ទី៥ | ៤២៩៦,១៧ | 0,00 | ៤២៩៦,១៧ | | | | | |
| ៨ | ប្លង់ជាន់ទី៦ | ៤២៩៦,១៧ | ៥៩៩,៧១ | ៣៦៩៦,៤៦ | | | | | |
| ៩ | ប្លង់ជាន់ទី៧ | ៤២៩៦,១៧ | 0,00 | ៤២៩៦,១៧ | | | | | |
| ១០ | ប្លង់ជាន់ទី៨ | ៤២៤១,០៦ | ៣១៣១,៦៣ | ១១០៩,៤៣ | | | | | |
| ១១ | ប្លង់ជាន់ទី៩ | ២៩៨៣,១០ | ២៥៧១,៧៨ | ៤១១,៣២ | | | | | |
| ១២ | ប្លង់ជាន់ទី១០ | ២៩៨៣,១០ | ២៥៧១,៧៨ | ៤១១,៣២ | | | | | |
| ១៣ | ប្លង់ជាន់ទី១១ | ២៩៨៣,១០ | ២៥៧១,៧៨ | ៤១១,៣២ | | | | | |
| ១៤ | ប្លង់ជាន់ទី១២ | ២៩៨៣,១០ | ២៥៧១,៧៨ | ៤១១,៣២ | | | | | |
| ១៥ | ប្លង់ជាន់ទី១៣ | ២៩៨៣,១០ | ២៥៧១,៧៨ | ៤១១,៣២ | | | | | |
| ១៦ | ប្លង់ជាន់ទី១៤ | ២៩៨៣,១០ | ២៥៧១,៧៨ | ៤១១,៣២ | | | | | |
| ១៧ | ប្លង់ជាន់ទី១៥ | ២៩៨៣,១០ | ២៥៧១,៧៨ | ៤១១,៣២ | | | | | |
| ១៨ | ប្លង់ជាន់ទី១៦ | ២៩៨៣,១០ | ២៥៧១,៧៨ | ៤១១,៣២ | | | | | |
| ១៩ | ប្លង់ជាន់ទី១៧ | ២៩៨៣,១០ | ២៥៧១,៧៨ | ៤១១,៣២ | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២០ | ប្លង់ជាន់ទី១៨ | ២៩៨៣,១០ | ២៥៧១,៧៨ | ៤១១,៣២ | | | | | |
| ២១ | ប្លង់ជាន់ទី១៩ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ២២ | ប្លង់ជាន់ទី២០ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ២៣ | ប្លង់ជាន់ទី២១ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ២៤ | ប្លង់ជាន់ទី២២ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ២៥ | ប្លង់ជាន់ទី២៣ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ២៦ | ប្លង់ជាន់ទី២៤ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ២៧ | ប្លង់ជាន់ទី២៥ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ២៨ | ប្លង់ជាន់ទី២៦ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ២៩ | ប្លង់ជាន់ទី២៧ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៣០ | ប្លង់ជាន់ទី២៨ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៣១ | ប្លង់ជាន់ទី២៩ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៣២ | ប្លង់ជាន់ទី៣០ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៣៣ | ប្លង់ជាន់ទី៣១ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៣៤ | ប្លង់ជាន់ទី៣២ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៣៥ | ប្លង់ជាន់ទី៣៣ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៣៦ | ប្លង់ជាន់ទី៣៤ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៣៧ | ប្លង់ជាន់ទី៣៥ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៣៨ | ប្លង់ជាន់ទី៣៦ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៣៩ | ប្លង់ជាន់ទី៣៧ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៤០ | ប្លង់ជាន់ទី៣៨ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៤១ | ប្លង់ជាន់ទី៣៩ | ២៩៨៣,១០ | ២៦៣៦,១១ | ៣៤៦,៩៩ | | | | | |
| ៤២ | ប្លង់ទៅ៉ាស់ដំបូល | ៣៣,៧២ | ០,០០ | ៣៣,៧២ | | | | | |
| សរុប | | ១៣៤.៦៨១,៧៣ | ៨៩.៣១៩,១២ | ៤៥.៣៦២,៦១ | ៦.០៧២,០០ | ១៤,៧១ | ១០ | ៤,៧១ | ២៨.៥៩៩,១២ |
| | | $FA_T$ | $FA_{TC}$ ឬ $FA_P$ | $FA_{TUC}$ | $SA_T$ | $FAR_P$ | $FAR_L$ | $FAR_{OL}$ | $FA_{OL}$ |

## ខ៧.ការគណនាតាមរូបមន្ត

### ១.ការគណនាសន្ទស្សន៍ប្រើប្រាស់ដី

- ឈ្មោះគម្រោង ៖ អគារពហុមុខងារ
- ទីតាំង ៖ ស្ថិតក្នុងតំបន់ចម្រុះ
- ផ្ទៃក្រឡាសរុបនៃដីឡូត៍ (**$SA_T$**) = ៦.០៧២,០០ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់ (**$FA_T$**) = ១៣៤.៦៨១,៧៣ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ (**$FA_{TC}$**) = ៨៩.៣១៩,១២ ម៉ែត្រក្រឡា
- ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ (**$FA_{TUC}$**) = ៤៥.៣៦២,៦១ ម៉ែត្រក្រឡា

តាមរយៈរូបមន្ត $$FAR = \frac{FA_{TC}}{SA_T}$$

ដូចនេះ សន្ទស្សន៍ប្រើប្រាស់ដី (**FAR**) = $\frac{៨៩.៣១៩,១២}{៦.០៧២,០០}$ = <u>១៤,៧១</u> (១)

ឬ តាមរយៈរូបមន្ត $$FAR = \frac{FA_T - FA_{TUC}}{SA_T}$$

ដូចនេះ សន្ទស្សន៍ប្រើប្រាស់ដី (**FAR**) = $\frac{១៣៤.៦៨១,៧៣ - ៤៥.៣៦២,៦១}{៦.០៧២,០០}$ = <u>១៤,៧១</u> (២)

### ២.ការគណនាផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ

តាមរយៈរូបមន្ត $FA_{TC} = FA_T - FA_{TUC}$

ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ (**$FA_{TC}$**) =១៣៤.៦៨១,៧៣–៤៥.៣៦២,៦១

= <u>៨៩.៣១៩,១២</u> ម៉ែត្រក្រឡា (៣)

### ៣.ការគណនាផ្ទៃក្រឡាកម្រាលសំណង់លើសកម្រិតកំណត់ផ្លូវការនៃសន្ទស្សន៍ប្រើប្រាស់ដី

តាមរយៈរូបមន្ត $FA_{OL} = FAR_{OL} \times SA_T$

ដោយៈ $FAR_{OL} = FAR_P - FAR_L$

- សន្ទស្សន៍ប្រើប្រាស់ដីស្នើសុំ (**$FAR_P$**) = ១៤,៧១
- សន្ទស្សន៍ប្រើប្រាស់ដីកំណត់ផ្លូវការ (**$FAR_L$**) = ១០

យោងតាមមាត្រា២២នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន **តំបន់ចម្រុះ** ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើ១០។

នាំឲ្យ សន្ទស្សន៍ប្រើប្រាស់ដីលើសការកំណត់ផ្លូវការ **($FAR_{OL}$)** = ១៤,៧១ – ១០ = ៤,៧១

ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់លើសសន្ទស្សន៍ **($FA_{OL}$)**= ៤,៧១ x ៦.០៧២,០០

=<u>២៨.៥៩៩,១២</u> ម៉ែត្រក្រឡា (៤)

ឬ តាមរយៈរូបមន្ត **$FA_{OL}$ = $FA_P$ – $FA_L$**

– ផ្ទៃក្រឡាកម្រាលសំណង់ស្នើសុំដោយសាមីសំណើ **($FA_P$)**ឬ **($FA_{TC}$)** = ៨៩.៣១៩,១២ ម៉ែត្រក្រឡា

– ផ្ទៃក្រឡាកម្រាលសំណង់កំណត់ផ្លូវការ **($FA_L$)** = **$FAR_L$ x $SA_T$**

= ១០ x ៦.០៧២,០០

= ៦០.៧២០,០០ ម៉ែត្រក្រឡា

ដូចនេះ ផ្ទៃក្រឡាកម្រាលសំណង់លើសសន្ទស្សន៍ **($FA_{OL}$)**=៨៩.៣១៩,១២ – ៦០.៧២០,០០

= <u>២៨.៥៩៩,១២</u> ម៉ែត្រក្រឡា (៥)

## ខ៣.ប្លង់ស្ថាបត្យកម្មគម្រោងស្នើសុំសាងសង់(ឧទាហរណ៍ទី២)



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ក្រោមដី (នីវ៉ូ -៤.៥០ម)**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ផ្ទាល់ដី**




ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី១**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី២**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី៣**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី៤**




ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី៥**




ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី៦**




ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី៧**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី៨**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី៩**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី១០ ដល់ជាន់ទី១៧**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី១៨**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី១៩**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់ជាន់ទី២០ ដល់ជាន់ទី៣៩**



ផ្ទៃក្រឡាកម្រាលសំណង់គិតសន្ទស្សន៍ ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍ **ប្លង់តេរ៉ាស់ដំបូល**